# សំណួរ

## តើអ្វីទៅជាការរំលោភសិទ្ធិមនុស្ស ( violation of human rights ) ?

## ចម្លើយ

ទង្វើខ្លះ អាចជាអំពើរំលោភច្បាប់ព្រហ្មទណ្ឌ និងមិនទាន់ត្រូវបានចាត់ថាជាការរំលោភសិទ្ធិមនុស្សទេ។ តើអ្វីទៅជាការរំលោភសិទ្ធិ និងដំណាក់កាលដែលគេអាចចាត់ថាមានការរំលោភសិទ្ធិ។

វាជាការបំពានសិទ្ធិ ជាទង្វើប៉ះពាល់ដល់សិទ្ធិ ដែលទទួលស្គាល់ណាមួយ ដែលធ្វើឲ្យម្ចាស់សិទ្ធិបាត់បង់ផលប្រយោជន៍។ ទង្វើមួយ ដូចជា ការវាយបង្ករបួសស្នាម វាជាអំពើបំពាននូវច្បាប់ព្រហ្មទណ្ឌ។ បុគ្គលជាជនរងគ្រោះ បានដាក់ពាក្យបណ្ដឹង អាជ្ញាធរបានចាត់ចែងស៊ើបអង្កេត ធ្វើការសវនាការ ដាក់ទោសទណ្ឌដល់ជនល្មើស និងបានសងជំងឺចិត្តជាក់ស្ដែងដល់ជនរងគ្រោះ (enforceable remedy)។ ករណីនេះ វាមិនមានជាការបំពានសិទ្ធិមនុស្សទេ។ និយាយជាសាមញ្ញ ដំណើរការនេះ បានគោរពទៅតាមការទាមទារ ដោយច្បាប់ និងស្របតាមវិធានសិទ្ធិមនុស្ស។ ផ្ទុយទៅវិញ ប្រសិនបើ គ្មានការស៊ើបអង្កេត នោះអាជ្ញាធរនឹងត្រូវបានចោទថា បំពានសិទ្ធិទទួលសំណងប្រកបដោយប្រសិទ្ធភាព (right to effective remedy) (មាត្រា ២នៃកតិកាសញ្ញាសិទ្ធិប្រជាពលរដ្ឋ ឆ្នាំ ១៩៦៧) ឬក្នុងអំឡុងពេលដំណើរការនីតិវិធី ជនល្មើសត្រូវបានលើកលែងទោស ដែលនេះ វានឹងប៉ះដល់សិទ្ធិទទួលបានការវិនិច្ឆ័យសេចក្ដីដោយតុលាការ (right to access to court) ឬជនរងគ្រោះត្រូវបានប្រព្រឹត្តមិនស្មើភាពនៅមុខតុលាការ ដែលអាចជាការបំពានគោលការណ៍ទទួលបានការការពារចំពោះមុខច្បាប់ ឬការមិនប្រព្រឹត្តិមិនរើសអើង (equal protection of law or non-discrimination) ឬ ការស៊ើបអង្កេតបង្អែបង្អង់យូរដោយគ្មានមូលហេតុសមស្រប ឬ ក្នុងអំឡុងពេលសវនាការ មិនបានគោរពតាមវិធាននីតិវិធីត្រឹមត្រូវ ដែលនាំឲ្យសវនាការមិនយុត្តិធម៌ បំពានសិទ្ធិ ទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ (right to fair trial) ។

ការបំពានសិទ្ធិ អាចមានសភាពធ្ងន់ធ្ងរ (gross violation) សំដៅលើការបំពានជាប្រព័ន្ធ ឬករណីខ្លះ បំពានលើសិទ្ធិតែមួយ ក៏ប៉ុន្តែ ដោយសារតម្លៃនៃសិទ្ធិប្រភេទនោះសំខាន់ គេក៏អាចហៅជាការពារសិទ្ធិធ្ងន់ធ្ងរ ខុសពីការបំពានសិទ្ធិ ដែលជាករណីតូចដាច់ដោយឡែកមួយ (isolated violation)។

ក្នុងន័យនេះ គេមិនអាចចេះតែចោទថា មានការបំពានសិទ្ធិ និងការរំលោភធ្ងន់ធ្ងរ ដោយគ្មានមូលទ្រឹស្ដីរឹងមាំពិតប្រាកដទេ។ អាជ្ញាធរ ដែលរដ្ឋខ្លួនបានចូលជាភាគី នៃកិច្ចព្រមព្រៀងអន្តរជាតិ និង

មានកាតព្វកិច្ចត្រូវគោរពនូវកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងនោះ ត្រូវចាត់វិធានការរស់រ៉ន់ បង្ការកុំឲ្យការបំពានច្បាប់ព្រហ្មទណ្ឌ ក្លាយជាការរំលោភសិទ្ធិមនុស្ស ដែលនាំឲ្យមានការទទួលខុសត្រូវ កាន់តែធ្ងន់ធ្ងរ និងផ្តល់សំណងជូនជនរងគ្រោះ។ សូមមើលសំណួរ និងចម្លើយមុន ស្តីពី ដំណោះស្រាយមានប្រសិទ្ធភាព (effective remedy)។

Further Readings: The Right to a Remedy and Reparation for Gross Human Rights Violations A Practitioners' Guide Revised Edition, 2018; Antoine Ruyse, Lost and Regained? Restitution as a Remedy for Human Rights Violations in the Context of International Law, ZaöRV 68 (2008), 129-153; Basic Principles and Guidelines on the Right to a Remedy and Reparation for Victims of Gross Violations of International Human Rights Law and Serious Violations of International Humanitarian Law, https://www.ohchr.org/EN/ProfessionalInterest/ Pages/ RemedyAndReparation.aspx